ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីវិជ្ជមានកូវីដ-១៩ ថ្មី ០១នាក់ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖**

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- *ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស* មានចំនួន ១២៣នាក់ (ស្មើនឹង ៩៨,៤០% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៣៩នាក់ និងបុរស ៨៤នាក់
- *អ្នកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត* មានចំនួន ០៣នាក់ (ជាបុរស)៖
  - បុរសជនជាតិខ្មែរ ០១ នាក់ ដែលបានវិលត្រឡប់មកពីប្រទេសហ្វីលីពីន និងបុរសជនជាតិខ្មែរ-បារាំង ដែលមានលទ្ធផលវិជ្ជមានវីរុសកូវីដ-១៩ ខាងក្រោមនេះ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
  - បុរសជនជាតិខ្មែរម្នាក់ទៀត កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តមិត្តភាពកម្ពុជា-ជប៉ុន មង្គលបូរី នៃខេត្តបន្ទាយមានជ័យ
- *អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់* នៅទូទាំងប្រទេស សរុបចំនួន ១២៦នាក់ (ស្ត្រី ៣៩នាក់ និងបុរស ៨៧នាក់)។

**២. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី៖ មាន ០១នាក់** នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០

បុរសជនជាតិខ្មែរ-បារាំងអាយុ ៣០ឆ្នាំ ធ្វើដំណើរមកពីប្រទេសបារាំងតាមជើងហោះហើរពីសាធារណរដ្ឋកូរ៉េ មកដល់កម្ពុជានៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២០ ស្នាក់នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលត្រូវបានក្រុមគ្រូពេទ្យយកវត្ថុសំណាករបស់គាត់ ទៅវិភាគឡើងវិញនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ក្នុងកំឡុងថ្ងៃទី១៣នៃការធ្វើចត្តាឡីស័កនៅផ្ទះរបស់គាត់ ដែលទទួលបានលទ្ធផល វិជ្ជមានវីរុសកូវីដ-១៩ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០។ បច្ចុប្បន្ន បុរសរូបនេះ ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

*(សំគាល់៖ លទ្ធផលវិភាគសំណាករបស់គាត់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ គឺអវិជ្ជមាន។ ប្រទេសដែលបុរសខាងលើនេះ បានធ្វើដំណើរ និងស្នាក់នៅរយៈពេល ១៤ថ្ងៃចុងក្រោយ មុនមកដល់កម្ពុជាគឺ ប្រទេសអង់គ្លេស ប្រទេសអាល្លឺម៉ង់ ប្រទេសបារាំង និងប្រទេសកូរ៉េ។)*

ក្រុមការងារឆ្លើយតបបន្ទាន់របស់ក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលរាជធានីភ្នំពេញ កំពុងបន្តធ្វើការស្រាវជ្រាវបន្ថែមទៀតដើម្បីរកអ្នកប៉ះពាល់។

**៣. ចំនួនធ្វើតេស្តអ្នកដំណើរតាមយន្តហោះសរុប ៖**

ចាប់តាំងពីថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០២០ មកដល់បច្ចុប្បន្ននេះ ចំនួនធ្វើតេស្តអ្នកដំណើរតាមយន្តហោះសរុបមាន ៣.៦៣៧នាក់ (ស្រី ៧៥៦នាក់ និងបុរស ២.៨៨១នាក់)។ ការធ្វើតេស្តសំណាកវត្ថុវិភាគនៅក្នុងចំនួនសរុបទាំងអស់នេះ មានលទ្ធផល វិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០៣នាក់ ដែលមានម្នាក់ជាស្ត្រីមកពីសហរដ្ឋអាមេរិក (បានព្យាបាលជាសះស្បើយហើយ) និងនៅសល់បុរសចំនួន ០២នាក់ទៀត កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត (ដូចមានបញ្ជាក់ជូនខាងលើនេះស្រាប់)។

**៤. ចំនួនធ្វើតេស្តសំណាកវត្ថុវិភាគសរុបទូទាំងប្រទេស ៖**

គិតចាប់តាំងពីខែមករា ឆ្នាំ២០២០ មកដល់បច្ចុប្បន្ននេះ វត្ថុសំណាកសរុបទូទាំងប្រទេសមានចំនួន ២១.៧៨៩សំណាក ដែលស្មើនឹង ១.៣១០សំណាក ក្នុងចំណោមប្រជាជនមួយលាននាក់ ដែលតួលេខនេះខ្ពស់ជាងបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអាទិត្យ ០២រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា



ទីស្តីការក្រសួងសុខាភិបាល ផ្ទះលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩